# សេចក្តីជូនដំណឹងអំពីការដោះស្រាយបណ្តឹងរួមនៃសេវាកម្ម IHSS

សេចក្តីជូនដំណឹងនេះនឹងធ្វើឡើងសម្រាប់សំណើដំណោះស្រាយបណ្តឹងរួមចំនួនពីរ។ សេចក្តីជូនដំណឹងនេះពាក់ព័ន្ធនឹងសេវាកម្មគាំទ្រនៅតាមផ្ទះ (IHSS)។

## អំពីបណ្តឹង

ក្នុងឆ្នាំ២០០៩ រដ្ឋកាលីហ្វ័រញ៉ាបានអនុម័តច្បាប់មួយដើម្បីបញ្ឈប់សេវាកម្ម IHSS ទាំងអស់ដែលបានផ្តល់ទៅឲ្យពលរដ្ឋចំនួនប្រហែល ៣០.០០០នាក់។ ច្បាប់នេះនឹងកាត់បន្ថយចំនួនម៉ោងធ្វើការសម្រាប់ជាជំនួយក្នុងការចម្អិនអាហារ សម្អាតផ្ទះ និងការថែទាំផ្ទះផ្សេងទៀតសម្រាប់ពលរដ្ឋចំនួន ១០០.០០០នាក់។ ក្នុងឆ្នាំ ២០១១ រដ្ឋកាលីហ្វ័រញ៉ាបានអនុម័តច្បាប់មួយផ្សេងទៀត ដើម្បីកាត់បន្ថយចំនួនម៉ោងសេវាកម្ម IHSS ចំនួន ២០ភាគរយសម្រាប់ពលរដ្ឋជាច្រើននាក់បន្ថែមទៀត។ (អ្នកទទួលសេវាកម្មមួយចំនួនអាចទទួលចំនួនម៉ោងធ្វើការរបស់ខ្លួនវិញ ប្រសិនបើពួកគេអាចបង្ហាញថា ខ្លួនកំពុងស្ថិតក្នុងស្ថានភាពមានហានិភ័យនៃការដែលគ្មានផ្ទះជំនួស)។

លោក David Oster និងអ្នកទទួលសេវាកម្ម IHSS ព្រមទាំងសហជីពកម្មករសម្រាប់បុគ្គលិកសេវាកម្ម IHSS បានដាក់ពាក្យប្តឹងពីបទកាត់បន្ថយម៉ោងសេវាកម្ម IHSS នេះ។ ចុងចោទគឺជាមន្ត្រីរដ្ឋកាលីហ្វ័រញ៉ា។ បណ្តឹងនោះត្រូវបានគេហៅថា *Oster ។*

ក្នុងឆ្នាំ២០០៩ រដ្ឋកាលីហ្វ័រញ៉ាក៏បានអនុម័តច្បាប់មួយដើម្បីកាត់បន្ថយមូលនិធិនៅពេលបុគ្គលិកសេវាកម្ម IHSS រកប្រាក់ចំណូលបានច្រើនជាង ៩,៥០ដុល្លារក្នុងមួយម៉ោង។

អ្នកទទួលសេវាកម្ម IHSS និងសហជីពកម្មករសម្រាប់បុគ្គលិកសេវាកម្ម IHSS បានដាក់ពាក្យប្តឹងពីបទកាត់បន្ថយប្រាក់ឈ្នួលនេះ។ ចុងចោទគឺជាមន្ត្រីរដ្ឋកាលីហ្វ័រញ៉ា។ ពាក្យបណ្ដឹងនោះត្រូវបានគេហៅថា *Dominguez*។

តុលាការនៅក្នុងទីក្រុង Oakland បានបញ្ឈប់ការកាត់បន្ថយចំនួនម៉ោងការងារ និងប្រាក់ឈ្នួលបណ្ដោះអាសន្ននៅក្នុងបណ្ដឹងទាំងពីរនេះកាលពីឆ្នាំ២០០៩ និង ២០១១។ រដ្ឋកាលីហ្វ័រញ៉ាបានស្នើឲ្យតុលាការកំពូល អនុញ្ញាតឲ្យខ្លួនបន្តសកម្មភាពកាត់បន្ថយសេវាកម្ម IHSS និងប្រាក់ឈ្នួលនេះបន្តទៀត។ គ្មាននរណាម្នាក់អាចប្រាប់បានទេថាតើតុលាការកំពូល អាចចេញសេចក្ដីសម្រេចយ៉ាងដូចម្ដេចនោះ។ គ្មាននរណាម្នាក់អាចប្រាប់បានទេថាតើតុលាការនៅក្នុងទីក្រុង Oakland នឹងបញ្ឈប់ការកាត់បន្ថយចំនួនម៉ោងការងារ និងប្រាក់ឈ្នួលនេះបានរហូតឬយ៉ាងណានោះទេ។

## អំពីដំណោះស្រាយ

រដ្ឋកាលីហ្វ័ញ៉ាបានយល់ព្រមបោះបង់ចោលការកាត់បន្ថយចំនួនម៉ោងការងារ និងប្រាក់ឈ្នួលនៃសេវាកម្ម IHSS ដែលបានធ្វើឡើងកាលពីឆ្នាំ២០០៩ និង ២០១១។

- ការកាត់បន្ថយចំនួនម៉ោង ២០ភាគរយនឹងមិនមានទៀតទេ។ ការកាត់បន្ថយចំនួនម៉ោងនឹងធ្វើឡើងក្នុងមួយឆ្នាំម្ដងក្នុងកម្រិត ៨ភាគរយ

ដោយចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ទៅ។ កម្រិត ៨ភាគរយនេះ ខ្ពស់ជាងកម្រិតកាត់បន្ថយចំនួនម៉ោងបច្ចុប្បន្ន ៤,៤ភាគរយ ពីព្រោះការកាត់បន្ថយ ៣,៦ភាគរយធ្វើឡើងរួចហើយ ដែលការកាត់បន្ថយនេះមិនមែនជាផ្នែកមួយនៃពាក្យបណ្តឹងនេះ (៣,៦ភាគរយ + ៤,៤ភាគរយ = ៨ភាគរយ)។

- ប្រហែលជានៅខែកក្កដា ឆ្នាំ២០១៤ ការកាត់បន្ថយចំនួនម៉ោងសេវាកម្ម IHSS នឹងធ្លាក់ចុះមកនៅត្រឹម ៧ភាគរយ (៣,៤ភាគរយលើកម្រិតដែលបានកាត់បន្ថយបច្ចុប្បន្ន ៣,៦ភាគរយ)។
- លោកអ្នកអាចស្នើឲ្យរដ្ឋបន្ថែមចំនួនម៉ោងថែមទៀត ប្រសិនបើស្ថានភាពរបស់លោកអ្នកផ្លាស់ប្តូរ។
- មូលនិធិរដ្ឋសម្រាប់ប្រាក់ឈ្នួលសេវាកម្ម IHSS នឹងមិនមាននោះទេ។

រដ្ឋកាលីហ្វ័រញ៉ាបានយល់ព្រមស្នើសុំថវិកាបន្ថែមទៀតសម្រាប់កម្មវិធី IHSS ពីរដ្ឋាភិបាលសហព័ន្ធសម្រាប់ការវាយតម្លៃថ្មីមួយ។ រដ្ឋកាលីហ្វ័រញ៉ាអាចបញ្ចប់ការកាត់បន្ថយចំនួនម៉ោងការងារ ៧ភាគរយក្នុងពេលឆាប់ៗនៅឆ្នាំ២០១៥ ប្រសិនបើមានការអនុញ្ញាត។

ខាងក្រោមនេះគឺជាបណ្តឹងរួម។ លោកអ្នកគឺជាសមាជិកនៃបណ្តឹង *Oster* ប្រសិនបើលោកអ្នកបានទទួលសេចក្តីជូនដំណឹងនៃបណ្តឹងអំពីការកាត់បន្ថយម៉ោងការងារនៅឆ្នាំ២០០៩ ឬបណ្តឹងកាត់បន្ថយប្រាក់ឈ្នួលនៃសេវាកម្ម IHSS នៅឆ្នាំ២០១១។ លោកអ្នកគឺជាសមាជិកមួយរូបនៃបណ្តឹងរួម *Dominguez* ប្រសិនបើ

លោកអ្នកទទួលបានសេវាកម្ម IHSS និងរស់នៅក្នុងទីក្រុងណាមួយក្នុងចំណោមទីក្រុងដូចក្រោមនេះ៖

| | | | |
|---|---|---|---|
| អាឡាមេដា | កាលាវេរ៉ាស | កុងត្រាកូស្តា | ហ្វ្រេសណូ |
| ឡូអែនជីឡែស | ម៉ាដេរ៉ា | ម៉ារីន | ម៉ារីប៉ូសា |
| មែនដូស៊ីណូ | ម៉ុងតេរ៉ី | ណាប៉ា | ប្លាស័រ |
| រីវែសាយ | សាក្រាមែនតូ | សែនបេនីតូ | សែនហ្វ្រាន់ស៊ីស្កូ |
| សែនវកឃីន | សែនល្វីអូប៊ីសកូ | សែនម៉ាតេអូ | សែនតា បាបារ៉ា |
| សែនតាក្លារ៉ា | សែនតាគ្រូស | សូឡាណូ | សូណូម៉ា |
| យ៉ូឡូ | យូបា | | |

ពាក់ព័ន្ធទៅនឹងដំណោះស្រាយទាំងនេះ សមាជិកបណ្តឹងរួមនៅក្នុងករណីទាំងពីរនេះមិនអាចដាក់ពាក្យប្តឹងពីបទកាត់បន្ថយម៉ោងធ្វើការងារ ៨ ឬ ៧ ភាគរយនោះបានទេ។

## ប្រសិនបើលោកអ្នកចង់បានព័ត៌មានលម្អិតបន្ថែមទៀត

មានមេធាវីផ្សេងៗគ្នា ដែលតំណាង ឲ្យសមាជិកបណ្តឹងរួមពាក់ព័ន្ធនឹងសេវាកម្ម IHSS នៅក្នុងករណី *Oster* និងករណី *Dominguez*។ បើមេធាវីក្នុងករណីទាំងពីរនេះរួមបញ្ចូលគ្នា មេធាវីទាំងនោះគេហៅថា **មេធាវីដោះស្រាយ*បណ្តឹង* IHSS។** លោកអ្នកអាចទទួលបានបញ្ជីឈ្មោះមេធាវីទាំងនេះ លិខិតថតចម្លងនៃកិច្ចព្រមព្រៀងដំណោះស្រាយ និងព័ត៌មានបន្ថែមទៀតទាក់ទងនឹងដំណោះស្រាយទាំងនេះពីការិយាល័យសុខុមាល ភាពទីក្រុងរបស់លោកអ្នក។ លោកអ្នក ក៏អាចទទួលបានព័ត៌មានបន្ថែមពីអាជ្ញាធរសាធារណៈប្រចាំទីក្រុងរបស់លោកអ្នកផងដែរ។ លោកអ្នកក៏អាចទទួលបានព័ត៌មានលម្អិតតាមរយៈគេហទំព័រខាងក្រោម

នេះផងដែរ៖ : www.disabilityrightsca.org, www.altshulerberzon.com, www.dss.cahwnet.gov, និង www.dhcs.ca.gov

**ដើម្បីសួរសំណួរ អំពីដំណោះស្រាយ ឬសេចក្តីជូនដំណឹងនេះ លោកអ្នកអាច៖**

(១) ផ្ញើសារទៅកាន់**មេធាវីដោះស្រាយបណ្តឹង IHSS** តាមរយៈ 1-866-752-6679.

(២) ផ្ញើសំបុត្រទៅកាន់**មេធាវីដោះស្រាយបណ្តឹង IHSS** តាមរយៈអាសយដ្ឋាន c/o Disability Rights California, Suite 500, 1330 Broadway, Oakland, CA 94612.

(3) ផ្ញើសាអេឡិចត្រូនិចទៅកាន់៖ **IHSSsettlement@gmail.com.**

**ប្រសិនបើលោកអ្នកមិនជំទាស់ទៅនឹងដំណោះស្រាយនេះទេ៖**

លោកអ្នកមិនត្រូវធ្វើអ្វីទាំងអស់។

**ប្រសិនបើលោកអ្នកជំទាស់ទៅនឹងដំណោះស្រាយនេះ៖**

លោកអ្នកត្រូវផ្ញើសាអេឡិចត្រូនិចនូវសេចក្តីថ្លែងការណ៍មួយអំពីថាតើហេតុអ្វីបានជាលោកអ្នកជំទាស់ទៅនឹងដំណោះស្រាយទាំងនោះ។ កាលបរិច្ឆេទកំណត់នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣។ សូមផ្ញើលិខិតជំទាស់របស់លោកអ្នកទៅកាន់៖

មេធាវីដោះស្រាយបណ្តឹង IHSSI តាមអាសយដ្ឋាន c/o Disability Rights California, Suite 500, 1330 Broadway, Oakland, CA 94612.

លោកអ្នកត្រូវផ្ញើលិខិតជំទាស់របស់លោកអ្នកមិនឲ្យហួសពីកាលបរិច្ឆេទកំណត់។ ផុតពីពេលនេះ លោកអ្នកមិនអាចជំទាស់ទៅនឹងដំណោះស្រាយនេះបានទេ។

តុលាការ នៅទីក្រុង Oakland ក៏នឹងបើកសវនការជំនុំជម្រះអំពីដំណោះស្រាយទាំងនេះនៅម៉ោង ២រសៀល នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៣។ ការបរិច្ឆេទនៃសវនការជំនុំជម្រះអាច ផ្លាស់ប្តូរបាន។ សូមទូរស័ព្ទទៅកាន់លេខ 1-866-752-6679 ឬចូលទៅកាន់គេហទំព័រ www.disabilityrightsca.org

ពេលជិតដល់ថ្ងៃសវនាការ។

អាសយដ្ឋានរបស់តុលាការគឺ

U.S. Federal District Court, Courtroom 2
1301 Clay Street, 4th Floor
Oakland California 94612

លោកអ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីសវនាការពីទីកន្លែងដែលបាននិយាយនៅខាងលើ។

يمكنك الحصول على هذا الإشعار باللغة العربية.

می توانید این اعلان را به زبان فارسی دریافت کنید.

Տվյալ ծանուցումը կարող եք ձեռք բերել նաև հայերեն լեզվով:

លោកអ្នកអាចទទួលលិខិតជូនដំណឹងនេះជាភាសាខ្មែរបាន។

您還可以得到此通知的中文版本。

본 공지를 한국어로 보실 수 있습니다.

Вы можете получить это уведомление на русском.

Usted puede obtener este aviso en español.

Bạn có thể nhận được thông báo này bằng tiếng Việt.

**Maari mong makuha ang punang ito sa Tagalog.**

Koj mus muab tau daim ntawv ceeb toom no hais ua lus Hmoob.

**You can get this notice in English.**